ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)

កិច្ចប្រជុំលើកទី 25

ថ្ងៃព្រហស្បតិ៍ ទី 9 ខែមេសា ឆ្នាំ 2026

ទីតាំង៖ Fisher Hill Elementary School, 59 Dexter Street, Orange, MA
ម៉ោង 6:30 ល្ងាច ដល់ 8:00 យប់

<u>កំណត់ហេតុកិច្ចប្រជុំ</u>

ទីកន្លែងប្រជុំ៖ ដោយផ្ទាល់

ឯកសារកិច្ចប្រជុំ៖ របៀបវារៈ ស្ពាយ

សមាជិកក្រុមប្រឹក្សា៖

- María Belén Power អនុរដ្ឋលេខាធិការរបស់ក្រុមប្រឹក្សា EEA ផ្នែកយុត្តិធម៌បរិស្ថាននិងសមធម៌ (EJ & Equity) (ផ្ទាល់)
- Marcos Luna (ផ្ទាល់)
- Cheryll Holley (ផ្ទាល់)
- Sofia Owen (ផ្ទាល់)
- Harleen Marwah (អនឡាញ)
- Lydia Lowe (អនឡាញ)
- Jen Salinetti (អនឡាញ)
- Paula Garcia (អនឡាញ)
- Melissa Harding Ferretti (អនឡាញ)
- Patricia Spence (អនឡាញ)
- Madeline Fraser Cook (អនឡាញ)
- Miles Gresham (អវត្តមាន)
- Kalila Barnett (អវត្តមាន)
- Caroline Hon (អវត្តមាន)
- Peter Maathey (អវត្តមាន)

1. **មតិស្វាគមន៍ និងទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ**
   María Belén Power បានស្វាគមន៍អ្នកចូលរួមទាំងអស់។

   Sophia Spungin បានជម្រាបជូនពីទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ រួមទាំងការប្រើប្រាស់ប្រអប់សំណួរនិងចម្លើយ (Q&A) និងលទ្ធភាពអាចទទួលបានអ្នកបកប្រែផ្ទាល់មាត់។

2. **ទិដ្ឋភាពទូទៅនៃរបៀបវារៈ**

   María Belén បានរំលឹកឡើងវិញអំពីរបៀបវារៈនៃកិច្ចប្រជុំ។

3. **ការហៅឈ្មោះសមាជិក/ការអនុម័តលើកំណត់ហេតុប្រជុំពីមុន**

María Belén បានណែនាំ **Harleen Marwah**
ជាសមាជិកថ្មីនៃក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន។

María Belén បានធ្វើការហៅឈ្មោះសមាជិកក្រុមប្រឹក្សា EJC។
នៅពេលចាប់ផ្តើមកិច្ចប្រជុំ សមាជិកក្រុមប្រឹក្សាដូចខាងក្រោមមានវត្តមានចូលរួម៖ Marcos Luna, Cheryll Holley, Sofia Owen, Harleen Marwah, Lydia Lowe, Jen Salinetti, Paula Garcia, Melissa Harding-Ferretti, Madeline Fraser Cook និង Patricia Spence។
សមាជិកក្រុមប្រឹក្សាដូចខាងក្រោមមិនមានវត្តមានចូលរួម៖ Miles Gresham, Kalila Barnett, Caroline Hon និង Peter Maathey។
María Belén បានបើកវេទិកាសម្រាប់
ការស្នើសុំមួយដើម្បីអនុម័តកំណត់ហេតុនៃកិច្ចប្រជុំ EJC លេខ 24 ថ្ងៃទី 12 ខែកុម្ភៈ ឆ្នាំ 2026។ **Cheryll Holley** បានស្នើសុំអនុម័ត។ **Lydia Lowe** បានគាំទ្រសំណើនេះ។
សមាជិកក្រុមប្រឹក្សាដែលមានវត្តមានទាំងអស់បានទទួលយកកំណត់ហេតុ។

4. **វគ្គសំណួរនិងចម្លើយជាសាធារណៈលើកទីមួយ**
អ្នកចូលរួមសាធារណៈតាមប្រព័ន្ធអនឡាញ បានផ្តល់យោបល់និងសំណួរ៖

- អ្នកចូលរួមម្នាក់មកពី Westfield
បានផ្តល់មតិយោបល់លើដំណើរការញត្តិចំនួនប្រជាជន EJ។
- អ្នកចូលរួមបានសម្តែងការព្រួយបារម្ភចំពោះដំណើរការញត្តិរយៈពេលប្រាំឆ្នាំ ដែលមិនទាន់ដោះស្រាយរួចរាល់នៅឡើយក្នុងការដាក់បញ្ចូល Westfield ជាសហគមន៍យុត្តិធម៌បរិស្ថានឡើងវិញ។
- អ្នកចូលរួមម្នាក់មកពី Taunton បានសម្តែងការព្រួយបារម្ភអំពីកង្វះការការពារពីគ្រោះថ្នាក់បរិស្ថាន ដែលបង្កដោយរោងចក្របេតុង ទោះបីជាតំបន់នេះត្រូវបានកំណត់ជាសហគមន៍យុត្តិធម៌បរិស្ថានក៏ដោយ។

មតិយោបល់ពីសំណួរនិងចម្លើយ មានរៀបរាប់ដូចខាងក្រោម

#	សំណួរ	ឈ្មោះអ្នកសួរ	ចម្លើយ
1	សូមអរគុណសម្រាប់ការលើកឡើងអំពីយន្តការដែលសង្កាត់នានាអាចដាក់ញត្តិសុំហាន: EJ។ តើអ្នកអាចជួយបញ្ជាក់ព័ត៌មាននៅក្នុងការពិភាក្សារបស់អ្នកអំពីអ្វីដែលនឹងកើតឡើងចំពោះសហគមន៍ដែលបានដាក់ញត្តិរួចហើយមុនយប់នេះដែរឬទេ? សូមអរគុណ។ ពី Westfield, MA	Kristen Mello	អនុរដ្ឋលេខាធិការ Power បាននិយាយថានាងនឹងតាមដានបន្តជាមួយ Kristen លើសំណួររបស់គាត់។
2	គណៈកម្មាធិការសកម្មភាពសង្គមនិងបរិស្ថានរបស់ Unitarian Universalist Fellowship of Falmouth គាំទ្រការកំណត់កុលសម្ព័ន្ធ Mashpee Wampanoag ជាប្រជាជន EJ។	David Dow	មិនបានឆ្លើយតបទេ។

	ក្រុម Sierra Club Cape Cod គាំទ្រការចាត់ទុកកុលសម្ព័ន្ធនេះជា អង្គភាពដាច់ដោយឡែកដែលមានសិទ្ធិសន្និសញ្ញា។		
3	គណៈកម្មាធិការសកម្មភាពសង្គម និងបរិស្ថាន (SEAC) នៃសមាគម UUC Falmouth ធ្វើការដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ ដោយសហការជាមួយបណ្តាញបរិស្ថានសហគមន៍សាសនានៅតំបន់ Cape Cod (ដែលមានសហគមន៍សាសនាចំនួន 60)។	David Dow	មិនបានឆ្លើយតបទេ។
4	តើសមាគមប្រជាពលរដ្ឋ Heritage នៅទីក្រុង Westfield ចាំបាច់ត្រូវដាក់ពាក្យសារជាថ្មីដែរឬទេ? ពួកគេបានដាក់ញត្តិរបស់ខ្លួនកាលពីខែកុម្ភៈ ឆ្នាំ 2025។	Kristen Mello	បច្ចុប្បន្ន គេមិនទាន់មានចម្លើយច្បាស់លាស់ទេថា តើអ្នកចាំបាច់ត្រូវដាក់ពាក្យសារជាថ្មី ឬយ៉ាងណានោះទេ។ ទោះជាយ៉ាងណាក៏ដោយ យើងនឹងពិភាក្សាអំពីរបៀបដែលយើងនឹងដាក់ពាក្យសារជាថ្មីដើម្បីកុំឱ្យពួកគេចាំបាច់ត្រូវដាក់ពាក្យម្តងទៀត។

5. **បទបង្ហាញស្តីពីផែនការថាមពលស្អាត និងអាកាសធាតុ**
   វាគ្មិន **Caroline Lemoine អនុប្រធានផ្នែកយុត្តិធម៌បរិស្ថាន** បានណែនាំសហវាគ្មិនផ្សេងទៀតរួមមាន **Eugene Benson**
   នាយកប្រតិបត្តិនៃសមាគមគណៈកម្មការអភិរក្សរដ្ឋ Massachusetts ស្នងការ Staci Rubin និង **Andrea Nyamekye មេដឹកនាំ**
   និងជាអ្នកយុទ្ធសាស្ត្រកម្មវិធីនៃសហជីពការងារសហគមន៍។

   វាគ្មិន **Eugene Benson** បានផ្តល់ទិដ្ឋភាពទូទៅនៃប្រវត្តិសាស្ត្រជុំវិញនិយមន័យប្រជាជន EJ នៅក្នុងរដ្ឋ Massachusetts។

   វាគ្មិន **Staci Rubin** បានផ្តល់ទិដ្ឋភាពទូទៅនៃការវិវឌ្ឍនៃនិយមន័យប្រជាជន EJ និងការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ដែលតែងតែធ្វើឡើងរៀងរាល់ 10 ឆ្នាំម្តង។
   វាគ្មិន **Andrea Nyamekye** បានផ្តល់ទិដ្ឋភាពទូទៅនៃនិយមន័យដែលបានកែសម្រួលនៅឆ្នាំ 2021 និងស្ថានភាពបច្ចុប្បន្ននៃនិយមន័យប្រជាជន EJ។
   វាគ្មិន **Caroline Lemoine** បានផ្តល់ទិដ្ឋភាពទូទៅនៃសេចក្តីព្រាងសំណើសម្រាប់ដំណើរការញត្តិថ្មី ដែលអនុញ្ញាតឱ្យមានផ្លូវសម្រាប់អ្នករស់នៅអាចដាក់ញត្តិទៅរដ្ឋមន្ត្រីដើម្បីចាត់តាំងសង្ឃាត់ ឬតំបន់ណាមួយជាប្រជាជន EJ។ **Caroline** បានផ្តល់ព័ត៌មានបន្ថែមអំពីលក្ខណៈវិនិច្ឆ័យសួរដែលសហគមន៍មួយគួរតែបំពេញ ទោះបីជាវាមិនបានដកពួកគេចេញពីដំណើរការនេះក៏ដោយ។ សមាជិកក្រុមប្រឹក្សាបានសាកសួរអំពីហេតុផលនៅពីក្រោយការកំណត់កាំរ៉ែងប្រាំម៉ាយល៍នៃសហគមន៍ EJ ការកំណត់អង្គភាពជំរឿនដែលកំណត់ដោយសហព័ន្ធ

លក្ខណៈវិនិច្ឆ័យដែលកំណត់សហគមន៍ EJ និងដំណើរការ
នៃការធ្វើបច្ចុប្បន្នភាពទិន្នន័យជំរឿន។

6. **បទបង្ហាញស្តីពីប្រព័ន្ធគ្រប់គ្រងជំនួយឥតសំណង**
   វាគ្មិន **Bill Hinkley ប្រធានផ្នែករដ្ឋបាលជំនួយឥតសំណងនៅការិយាល័យ**
   ប្រតិបត្តិកិច្ចការថាមពល និងបរិស្ថាន
   បានផ្តល់ទិដ្ឋភាពទូទៅនៃប្រព័ន្ធគ្រប់គ្រងជំនួយឥតសំណងថ្មីនៅ EEA។ **Bill**
   បានគូសបញ្ជាក់ពីមុខងារសំខាន់ៗ និងសារៈសំខាន់របស់វាសម្រាប់ក្រុមការងារ និងដៃគូ
   ព្រមទាំងបានពន្យល់ពីប្រព័ន្ធផតថល និងពិនិត្យឡើងវិញពីរបៀបដាក់ពាក្យស្នើសុំ
   និងគ្រប់គ្រងពាក្យស្នើសុំជំនួយឥតសំណង។ សមាជិកក្រុមប្រឹក្សាបានសាកសួរអំពី
   ដែនកំណត់នៃលទ្ធភាពប្រើប្រាស់ ការប្រើប្រាស់ភាសា សមត្ថភាពក្នុងការធ្វើ
   ការលើជំនួយនេះនៅក្រៅផតថល ការបើកដំណើរការការជូនដំណឹង
   និងមុខងារបន្ថែមនៃផតថលគ្រប់គ្រងជំនួយឥតសំណងថ្មីនេះ។

7. **វគ្គសំណួរ និងចម្លើយសាធារណៈលើកទីពីរ**
   - អ្នកចូលរួមតាមអនឡាញម្នាក់បានលើកទឹកចិត្តថាសមាគមអ្នករស់នៅ
     Heritage
     មិនគួរតម្រូវឱ្យដាក់ពាក្យស្នើសុំឡើងវិញតាមរយៈដំណើរការឮគ្គិចំនួនប្រជាជន EJ
     នោះទេ។

   មតិយោបល់ពីសំណួរនិងចម្លើយ មានរៀបរាប់ដូចខាងក្រោម

#	សំណួរ	ឈ្មោះអ្នកសួរ	ចម្លើយ
1	ប្រជាជន EJ នៅតំបន់អាងរងទឹកភ្លៀង Waquoit Bay លើ Cape Cod កំពុងប្រឈមនឹងសម្ពាធបរិស្ថាននានា ដូចជាការប្រែប្រួលអាកាសធាតុ ការបំពុលដោយសារធាតុចិញ្ចឹមពីប្រព័ន្ធអាងចម្រោះទឹកស្អុយ សារធាតុគីមីពុល (methyl mercury, PFAS, មីក្រូប្លាស្ទិក និងណាណូប្លាស្ទិក ។ល។) ការនេសាទហួសកម្រិត បញ្ហា EJ និងកង្វះលំនៅឋានដែលមានតម្លៃសមរម្យ/អាចទិញបានសម្រាប់បុគ្គលិកសេវាកម្ម ។ល។	David Dow	មិនបានឆ្លើយតបទេ។
2	រជាយការណ៍វាយតម្លៃហានិភ័យប្រព័ន្ធអេកូឡូស៊ីតំបន់អាងរងទឹកភ្លៀង Waquoit Bay របស់ទីស្នាក់ការកណ្តាល ដែលបានចេញផ្សាយក្នុងឆ្នាំ 2004 បានលើកយកសម្ពាធមួយចំនួនទាំងនេះមកដោះស្រាយ។	David Dow	មិនបានឆ្លើយតបទេ។

3	ខ្ញុំបានដាក់មតិយោបល់ផ្ទាល់ខ្លួនទៅកាន់អង្គភាពវិស្វកម្មកងទ័ពសហរដ្ឋអាមេរិក ស្តីពីផែនការមេព្រៃកជីក Cape Cod ដោយស្នើសុំការចូលរួមផ្តល់មតិពី EFC រដ្ឋ Massachusetts ព្រមទាំងបញ្ជូលមតិយោបល់របស់ក្រុម Sierra Club Cape Cod ទាក់ទងនឹងការផ្លាស់ប្តូរស្ពាន Bourne និង Sagamore រួមទាំងការពង្រីកបំពង់ឧស្ម័នធម្មជាតិដែលនឹងបង្កើនការសាងសង់លំនៅឋាននៅលើតំបន់ធម្មជាតិបច្ចុប្បន្ន។ គណៈកម្មាធិការ UUC SEAC នឹងរៀបចំសិក្ខាសាលាជាបន្តបន្ទាប់តាម Zoom នៅក្នុងខែឧសភា អំពីបញ្ហាប្រឈមនេះ។	David Dow	មិនបានឆ្លើយតបទេ។
4	តើអ្នកនឹងពិចារណាលើសំណើជំនួយដែលផ្តោតលើភាគល្អិតតូចៗ និងសំឡេងរំខានពីការដឹកជញ្ជូនដែរឬទេ? សូមអរគុណ - Wig	Wig Zamore	អាស្រ័យលើឱកាសផ្តល់ប្រាក់ជំនួយ និងវិសាលភាពដែលមាននៅក្នុងកម្មវិធីជំនួយនោះ។ Bill បានលើកឡើងអំពីកម្មវិធីជំនួយមួយចំនួនដែលកំពុងបើកដំណើរការឥឡូវនេះ។ ខ្ញុំសូមលើកទឹកចិត្តឱ្យអ្នកចូលទៅកាន់ប្រព័ន្ធគ្រប់គ្រងការផ្តល់ជំនួយ ដើម្បីស្វែងរកឱកាសដែលកំពុងបើកទទួល។

8. **ជំហានបន្ទាប់ និងការបិទប្រជុំ**

María Belén បានប្រកាសជ្រាប់សមាជិកក្រុមប្រឹក្សាថា ការិយាល័យ EJ និងសមធម៌ នឹងដឹកនាំដំណើរការជាមួយក្រុមការងារអាកាសធាតុ ដើម្បីបង្កើតក្របខ័ណ្ឌ និងតំរូវសម្រាប់បណ្តាញអគ្គិសនីខ្នាតតូច និងកំណត់បរិមាណអត្ថប្រយោជន៍សហគមន៍។
María Belén បានរំលឹកដល់សមាជិកក្រុមប្រឹក្សាអំពីកិច្ចប្រជុំបន្ទាប់នៅ**ថ្ងៃទី 11 ខែមិថុនា នៅ Amherst**។
María Belén បានស្នើសុំសំណើមួយដើម្បីបញ្ចប់កិច្ចប្រជុំ។ **Patricia Spence** បានស្នើសុំឱ្យការបិទ។ **Melissa Harding-Ferretti** បានគាំទ្រ។ Sophia Spungin បានធ្វើការហៅឈ្មោះ
ហើយសមាជិកក្រុមប្រឹក្សាដែលមានវត្តមានទាំងអស់បានអនុម័ត។
កិច្ចប្រជុំបានបញ្ចប់នៅម៉ោង **8:02 យប់**។